01530390

**Declassified to Public**
**12 June 2020**

លេខ៖ D353/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 09 / 2017
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧

ភាសា ៖ អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ យោងតាមវិធានផ្ទៃក្នុង ៥៣ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានចេញ*ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា* ("ដីកាសន្និដ្ឋាន") ដែលក្នុងនេះ គាត់បានធ្វើការចោទប្រកាន់ផ្សេងៗ ដូចជា អោ អាន ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិមួយចំនួន[1]។ ដោយសារមានករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទើបសហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីបញ្ជូនដីកាសន្និដ្ឋានជូនទៅ ស.ច.ស នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[2]។

៣. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥ និងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបន្ថែម ដោយស្នើសុំ ស.ច.ស ទទួលពិនិត្យការចោទប្រកាន់ថ្មីមកលើអោន អាន យោងតាមវិធានផ្ទៃក្នុង៥៥(៣)[3]។

៤. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ បន្ទាប់ពីចុះហត្ថលេខាលើករណីខ្វែងយោបល់គ្នាជាមួយ ស.ច.ស.ជាតិ រួចមក អតីត ស.ច.ស.អន្តរជាតិ Harmon បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទរំលោភលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦(មនុស្សឃាត)

---

[1] សំណុំរឿង ០០៤/២ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[2] សំណុំរឿង ០០៤/២ ឯកសារ D1/1 *សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[3] សំណុំរឿង ០០៤/២ ឯកសារ D65 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ។ សំណុំរឿង ០០៤/២ ឯកសារ D191 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ* ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។ សំណុំរឿង០០៤/២ ឯកសារ D254/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តគាមះ* ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥។ សំណុំរឿង ០០៤/២ ឯកសារ D272/1 *ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរលើអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ១ និងតំបន់ ៤ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។*

និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នូវការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត[4]។ នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ស.ច.ស.អន្តរជាតិ Bohlander បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទអំពើប្រល័យពូជសាសន៍ និងបទចោទបន្ថែមទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[5]។

៥. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស.ច.ស បានចេញ*សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* យោងតាមវិធានផ្ទៃក្នុង ៦៦(១) ហើយបានបង្គាប់ឲ្យបំបែកនីតិវិធី អោ អាន ចេញពីសំណុំរឿង ០០៤[6]។

៦. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ ក្រោយពីបានបញ្ចប់កិច្ចស៊ើបសួរបន្ថែមទៀតរួចមក ស.ច.ស បានចេញ*សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* យោងតាមវិធានផ្ទៃក្នុង ៦៦(១)[7]។

៧. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ស.ច.ស បានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា ដើម្បីឲ្យចេញដីកាសន្និដ្ឋានស្ថាពរ យោងតាមវិធានផ្ទៃក្នុង ៦៦(៤)[8]។

៨. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្ដី អោ អាន (“មេធាវីការពារក្ដី”) បានដាក់*សំណើសុំការបញ្ជាក់បំភ្លឺ* ទាក់ទងនឹងការដែលអាចមានដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាដាក់ដោយសហព្រះរាជអាជ្ញា(“សំណើ”)[9]។

---

[4]សំណុំរឿង ០០៤/២ ឯកសារ D242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[5]សំណុំរឿង ០០៤/២ ឯកសារ D303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀតរបស់ អោ អាន* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦។

[6]សំណុំរឿង ០០៤/២ ឯកសារ D334 *សេចក្ដីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។ សំណុំរឿង ០០៤/២ ឯកសារ D334/1 *ដីកាសម្រេចបំបែកនីតិវិធី អោ អាន ចេញពីសំណុំរឿង ០០៤* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។

[7]សំណុំរឿង ០០៤/២ ឯកសារ D334/2 *សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧។

[8]សំណុំរឿង ០០៤/២ ឯកសារ D351 *ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤)នៃវិធានផ្ទៃក្នុង* ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧។

[9]សំណុំរឿង ០០៤/២ ឯកសារ D353 *សំណើសុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧។

៩. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាជាតិ (“ស.ព.ជ”) បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/២ [10]។

១០. នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ស.ព.អ បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/២[11]។

## II. **សារណា**

### ក. ការបង្ហាញថាមានដីកាសន្និដ្ឋានស្ថាពរច្រើន

១១. មេធាវីការពារក្តី អះអាងថា ខ្លួនមិនច្បាស់ថាតើត្រូវរំពឹងថាមានដីកាសន្និដ្ឋានស្ថាពរមួយ ឬ ពីរ ពីសហព្រះរាជអាជ្ញា ពីព្រោះថា វាមិនមានភាពច្បាស់ថា ស.ព.ជ បានបំពេញតួនាទីអ្វីខ្លះនៅក្នុងសំណុំរឿងនេះ ចាប់តាំងពី មានករណីខ្វែងយោបល់គ្នាអំពីការដាក់ដីកាសន្និដ្ឋាន ការយោងក្នុងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ គឺប្រើពាក្យ *“របស់គាត់”* (នៅក្នុងចម្លើយតបរបស់ ស.ច.ស អន្តរជាតិ) និង ដីកាសន្និដ្ឋានស្ថាពរ(*“របស់ ស.ព.អ”*) ដោយឡែកៗ ហើយនៅក្នុងសំណុំរឿង ០០៤/១ ស.ព.អ និង ស.ព.ជ បានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នាផងដែរ[12]។

១២. ហេតុនេះ ក្នុងគោលបំណងដើម្បីតម្លាភាព សច្ចភាពផ្លូវច្បាប់ និងការពារសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរមួយ(ឬច្រើន) មេធាវីការពារក្តី ស្នើសុំការបញ្ជាក់បំភ្លឺអំពីគោលបំណងរបស់សហព្រះរាជអាជ្ញា (“សំណើ ទី ១”) [13]។

---

[10]សំណុំរឿង ០០៤/២ ឯកសារ D351/4 *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧។

[11]សំណុំរឿង ០០៤/២ ឯកសារ D351/5 *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧។

[12]សំណើ កថាខណ្ឌ ២-៣, ២១-២៤។

[13]ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៤។

01530394



## ខ. ភាពស្របច្បាប់នៃការដាក់ដីកាសន្និដ្ឋានស្ថាពរច្រើន

១៣. មេធាវីការពារក្តី អះអាងថា ពាក្យពេចន៍នៃវិធានផ្ទៃក្នុង ៦៦(៥) និង មាត្រា ១៦ នៃច្បាប់ អ.វ.ត.ក បង្ហាញថា មានតែដីកាសន្និដ្ឋានស្ថាពរតែមួយទេដែលគួរដាក់ដោយការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សំណុំរឿងមួយ[14]។ បន្ថែមពីលើនេះ បទប្បញ្ញត្តិដែលចែងអំពីយន្តការដោះស្រាយករណីខ្វែងយោបល់គ្នាលើដីកាសន្និដ្ឋានស្ថាពរ (ដូចមានចែងនៅវិធានផ្ទៃក្នុង ៧១(៣)(គ)) *"បង្ហាញយ៉ាងច្បាស់"* ថា មិនមានចេតនាឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរពីរផ្ទុយគ្នាឡើយ។ មេធាវីការពារក្តី ផ្តល់ទឡ្ហីករណ៍ថា ប្រសិនបើធ្វើដូច្នេះមែននឹងអាចឱ្យ ស.ច.ស *"ដណ្តើមយកអំណាចផ្តាច់មុខ* របស់អង្គបុរេជំនុំជម្រះ("អ.ប.ជ") *យ៉ាងស្រួល"* ដើម្បីដោះស្រាយជម្លោះទាក់ទងនឹងដីកាសន្និដ្ឋានស្ថាពរ[15]។

១៤. មេធាវីការពារក្តី អះអាងថា តថភាព និងគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បង្ហាញឱ្យឃើញថា ការិយាល័យអយ្យការដែលមិនអាចឯកភាពគ្នាលើអង្គសេចក្តីនៃសំណុំរឿងណាមួយ មិនគួរបន្តដំណើរការនីតិវិធីសំណុំរឿងនោះទេ ហើយមេធាវីការពារក្តី ចោទសួរថាតើក្នុងចំណោមដីកាសន្និដ្ឋានស្ថាពរពីរដែលមានទម្ងន់ស្មើគ្នា ប៉ុន្តែមានខ្លឹមសារផ្ទុយគ្នា គេគួរពិចារណាយកមួយណាដែលតំណាងឱ្យរឿងក្តីរបស់អយ្យការ[16]។ ចុងក្រោយ មានការអះអាងថា ការមិនបានជំទាស់ទាំងស្រុងទៅលើនីត្យានុកូលភាពនៃការដាក់ដីកាសន្និដ្ឋានស្ថាពរពីរនៅក្នុងសំណុំរឿង ០០៤/១ មិនអាចទប់ស្កាត់មិនឱ្យជំទាស់នៅក្នុងសំណុំរឿង ០០៤/២ ឡើយ[17]។

១៥. ហេតុនេះ ដើម្បីផលប្រយោជន៍ការពារសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានកិច្ចស៊ើបសួរ និងការជំនុំជម្រះស្របតាមច្បាប់ មេធាវីការពារក្តី ស្នើសុំការបំភ្លឺថាតើការដាក់ដីកាសន្និដ្ឋានស្ថាពរពីរនៅក្នុងសំណុំរឿងតែមួយ គឺអនុលោមតាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងដែរឬអត់ ("សំណើទី ២")[18]។

---

[14] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៥។

[15] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៧, ៣៤។

[16] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៦។

[17] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៨។

[18] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៩, ៣៤។

01530395



## គ. យន្តការដោះស្រាយករណីខ្វែងយោបល់យោងតាមវិធានផ្ទៃក្នុង ៧១

១៦. មេធាវីការពារក្តី អះអាងថា តាមខ្លឹមសារសាមញ្ញនៃមាត្រា ២០ ថ្មីនៃច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង៧១ ការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាអំពីដីកាសន្និដ្ឋានស្ថាពរ "*ត្រូវ*" តែដោះស្រាយឱ្យស្របតាមយន្តការដំណោះស្រាយ ដែលមានចែងក្នុងបទប្បញ្ញត្តិទាំងនេះ[19]។ ជាងនេះទៀត ដោយសារថា ចាំបាច់តម្រូវឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរ យោងតាមវិធានផ្ទៃក្នុង ៦៦(៥) ការខ្វែងយោបល់គ្នាណាមួយត្រូវតែពាក់ព័ន្ធនឹង*ខ្លឹមសារ*នៃដីកាសន្និដ្ឋានស្ថាពរ[20]។

១៧. តាមសំអាងហេតុទាំងនេះ និងតាមសំអាងហេតុដូចបានសង្ខេបនៅផ្នែកខាងលើ មេធាវីការពារក្តី បញ្ជាក់ថា សហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវស្វែងរកមធ្យោបាយទាំងអស់ដែលអាចមានយោងតាមវិធានផ្ទៃក្នុង ៧១ ដើម្បីដោះស្រាយជម្លោះដែលពាក់ព័ន្ធនឹងដីកាសន្និដ្ឋានស្ថាពរមួយ ជាជាងដាក់ដីកាសន្និដ្ឋានស្ថាពរពីរដែលផ្ទុយគ្នា[21]។ មេធាវីការពារក្តី អះអាងថា ការមិនបានធ្វើដូច្នេះនឹងធ្វើឱ្យ អោ អាន បាត់បង់"*សិទ្ធិ*"ទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុអំពីការខ្វែងយោបល់គ្នា ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៧១(៤)(ឃ)។ ជាងនេះទៀត អោ អាន មាន"*ក្តីរំពឹងយ៉ាងសមហេតុផល*"ថា អ.ប.ជ នឹងដោះស្រាយករណីខ្វែងយោបល់គ្នាបែបនេះ តាមគោលបំណងរបស់ភាគីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា[22]។

១៨. មេធាវីការពារក្តី កត់សម្គាល់ថា វិធានផ្ទៃក្នុងមិនបានបញ្ជាក់ពីចំណុចពេលវេលាដំបូងបំផុតដែលករណីខ្វែងយោបល់អំពីដីកាសន្និដ្ឋានស្ថាពរអាចដាក់បានឡើយ ហើយអះអាងទៀតថា ដោយពិចារណាលើសារៈសំខាន់នៃបញ្ហាចោទទាំងនេះ សហព្រះរាជអាជ្ញា ត្រូវតែធ្វើសេចក្តីសម្រេចដោយប្រាប់ព័ត៌មានអំពីគោលជំហររៀងខ្លួនរបស់សហព្រះរាជអាជ្ញា។ មេធាវីការពារក្តី អះអាងថា យន្តការដោះស្រាយករណីខ្វែងយោបល់ អាចយកមកប្រើបានតែនៅពេលដែលដីកាសន្និដ្ឋានស្ថាពរទាំងពីរបានបញ្ចប់ជាស្ថាពរតែប៉ុណ្ណោះ[23]។

---

[19]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣០។

[20]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣១។

[21]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣១។

[22]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣១។

[23]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣២។

01530396



១៩. ហេតុនេះ មេធាវីការពារក្តី ស្នើសុំការបញ្ជាក់បំភ្លឺអំពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា យោងតាមវិធានផ្ទៃក្នុង ៧១ (រួមមាន ថាតើ សហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុងនូវវិធានការដោះស្រាយជម្លោះដែរឬអត់ និងការបំភ្លឺអំពីចំណុចពេលវេលាដំបូងបំផុតដែលវិធានការបែបនេះគួរចាប់ផ្តើមអនុវត្ត)("សំណើទី ៣")[24]។

### ឃ. ផលប៉ះពាល់មកលើពេលវេលានៃការចេញដីកាសន្និដ្ឋានស្ថាពរ

២០. ចុងក្រោយ ដោយពិនិត្យឃើញថា មេធាវីការពារក្តី មានសិទ្ធិត្រូវដឹងនៅពេលណាដែលករណីខ្វែងយោបល់គ្នាមានផលប៉ះពាល់មកលើសិទ្ធិ និងផលប្រយោជន៍របស់ អោ អាន មេធាវីការពារក្តី ស្នើសុំការបញ្ជាក់បំភ្លឺអំពីផលប៉ះពាល់ណាមួយ ដែលករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទំនងជាអាចមានមកលើពេលវេលានៃការចេញដីកាសន្និដ្ឋានស្ថាពរ("សំណើទី ៤")[25]។

## III. ពិភាក្សា

២១. ការពិចារណារបស់យើងអំពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា យោងតាមវិធានផ្ទៃក្នុង ៧១ គឺពាក់ព័ន្ធនឹងការពិចារណារបស់យើងអំពីភាពស្របច្បាប់ នៃការដាក់ដីកាសន្និដ្ឋានស្ថាពរពីរ ដែលស្ថិតនៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ហើយការពិចារណាទាំងពីរនេះគឺពាក់ព័ន្ធគ្នាចំពោះករណីសំណើទី១។ ហេតុនេះ យើងនឹងដោះស្រាយបញ្ហាទាំងនេះទៅតាមលំដាប់លំដោយនេះ។

### ក. យន្តការដោះស្រាយករណីខ្វែងយោបល់យោងតាមវិធានផ្ទៃក្នុង ៧១ (សំណើទី ៣)

២២. ការគ្រប់គ្រងលើកិច្ចការផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា រាប់បញ្ចូលទាំងបញ្ហាទាក់ទងនឹងករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា(ដែលជាការសម្ងាត់[26]) គឺស្ថិតនៅក្រៅដែនអំណា

---

[24] ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣៣,៣៤។

[25] ដូចជើងទំព័រខាងលើ។

[26] យោងតាមវិធានផ្ទៃក្នុង ៧១(២) ឯកសារអំណះអំណាងដែលទាក់ទងនឹងអង្គហេតុ និងមូលហេតុនៃការខ្វែងយោបល់គ្នា មិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ។

01530397



ចរបស់ ស.ច.ស[27]។ ប៉ុន្តែ បញ្ហាចោទថាតើ ការដាក់ឯកសារពីសហព្រះរាជអាជ្ញា អនុលោមតាមច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តន៍ដែរឬអត់ និងថាតើឯកសារទាំងនោះអាចទទួលយកឬអត់នោះ គឺជាបញ្ហាដែល ស.ច.ស ត្រូវតែពិចារណាដោះស្រាយ។

២៣. ដោយសារថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរ គឺជាភ័ស្តុតាងបញ្ជាក់ពីការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ទើប បញ្ហាចោទថាតើសហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុងនូវវិធានការដោះស្រាយជម្លោះដែរឬអត់ និយាយម្យ៉ាងទៀត ថាតើយន្តការដោះស្រាយយោងតាមវិធានផ្ទៃក្នុង ៧១ គឺជាលក្ខខណ្ឌតម្រូវ ឬក៏ជាឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា គឺពិតជាបញ្ហាចោទដែលស្ថិតនៅក្នុងដែនអំណាចរបស់យើង ពីព្រោះថា បញ្ហាចោទនេះពាក់ព័ន្ធនឹងការដែលអាចទទួលយកដីកាសន្និដ្ឋានស្ថាពរ។ ប៉ុន្តែ លក្ខណៈទូទៅជាងនេះនៃសំណើទី ៣ ដែលសុំបំភ្លឺអំពីកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញា ដូចមានចែងជាទូទៅនូវវិធានផ្ទៃក្នុង ៧១ គឺមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ទេ ហើយយើងនឹងមិនធ្វើការប៉ាន់ស្មានអំពីចំណុចដែលមេធាវីការពារក្តី តម្រូវឱ្យបំភ្លឺទេ។

២៤. មាត្រា ២០ ថ្មីនៃច្បាប់ អ.វ.ត.ក ចែងថា ប្រសិនបើសហព្រះរាអាជ្ញាខ្វែងយោបល់ នីតិវិធីដោះស្រាយ *"ត្រូវ"*យកមកអនុវត្ត ប៉ុន្តែ បទប្បញ្ញត្តិបន្ទាប់ពីមានការចែងបែបនេះ ហាក់ដូចជាបង្ហាញយ៉ាងច្បាស់ថាការប្រើប្រាស់នីតិវិធីដោះស្រាយជម្លោះ គឺជាឆន្ទានុសិទ្ធិ៖ *"ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម"*[28]។ចំណុចនេះឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា[29]ហើយស្របតាមខ្លឹមសារនៃវិធានផ្ទៃក្នុង៧១ ដែលក្រៅពីមានចែងអំពីនីតិវិធីបន្ថែមជាមុនអំពីការធ្វើកំណត់ហេតុករណីខ្វែងយោបល់នោះក៏ចែងថា ក្នុងករណីមានការ

[27] *សូមមើល* សេចក្តីពិចារណារបស់ចៅក្រមអន្តរជាតិ នៃ អ.ប.ជ នៅក្នុងសំណុំរឿង ០០៣ ឯកសារ D20/4/4 (សំណៅកោសលុប) *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣* ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ មតិយោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៨។

[28]ច្បាប់ អ.វ.ត.ក មាត្រា ២០ ថ្មី (គូសបញ្ជាក់បន្ថែម)។

[29]កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ("កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា") មាត្រា ៦(៤)។

ខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា *"សហព្រះរាជអាជ្ញាណាមួយ ឬទាំងពីរអាចធ្វើកំណត់ហេតុ"*ករណីខ្វែងយោបល់គ្នានេះនៅក្នុងសំណុំឯកសារខ្វែងយោបល់ ហើយក្នុងរយៈពេល ៣០ ថ្ងៃនៃការចុះកំណត់ហេតុករណីខ្វែងយោបល់នេះ *"សហព្រះរាជអាជ្ញាណាម្នាក់អាចនាំយកករណីខ្វែងយោបល់នេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ"*[30]។

២៥. ទោះបីជាមានការចែងខាងលើក៏ដោយ ក៏ចៅក្រមជាតិនៃ អ.ប.ជ ធ្លាប់បានបញ្ជាក់ថា សហព្រះរាជអាជ្ញាម្នាក់មិនអាចបំពេញកិច្ចដោយឯកតោភាគីបានឡើយ ប្រសិនបើមិនទាន់បានផ្ទេរសិទ្ធិអំណាចឱ្យធ្វើដូច្នេះយោងតាមវិធានផ្ទៃក្នុង ១៣(៣) ឬក៏ អ.ប.ជ មិនទាន់បានពិនិត្យដោះស្រាយករណីខ្វែងយោបល់គ្នានេះទេ[31]។ ប៉ុន្តែ ក្រោយមកទៀតនៅក្នុងសាលដីកាមួយជាឯកច្ឆ័ន្ទ អ.ប.ជ បានរំឭកថា ខ្លួនធ្លាប់បានបញ្ជាក់ថា សហព្រះរាជអាជ្ញាម្នាក់ ឬ ស.ច.ស ម្នាក់ អាចបំពេញកិច្ចដោយឯកតោភាគីបាន ប្រសិនបើបានចុះកំណត់ហេតុករណីខ្វែងយោបល់ ហើយរយៈពេលដែលត្រូវបញ្ជូនករណីខ្វែងយោបល់ទៅចំពោះមុខ អ.ប.ជ បានផុតរលត់ហើយ[32]។ ដោយរំឭកពីសាលដីកានេះ ចាប់តាំងពីពេលនោះមក អ.ប.ជ បានបញ្ជាក់ថា ដីកាកោះចេញដោយឯកតោភាគីគឺមានសុពលភាព *"ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់ដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងត្រូវបានអនុវត្តរួច ហើយរយៈពេល៣០ ថ្ងៃសម្រាប់ការដាក់សំណើទៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុតហើយ"*[33]។ ការដែលមិនចាំបាច់តម្រូវឱ្យបញ្ជូនករណីខ្វែងយោបល់គ្នាទៅ អ.ប.ជ មុនពេលបំពេញកិច្ចដោយឯកតោ

---

[30]វិធានផ្ទៃក្នុង ៧១(១), (២)(គូសបញ្ជាក់បន្ថែម)។

[31]សំណុំរឿង ០០៣ ឯកសារ D20/4/4 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣*ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ៧, ១១។

[32]សំណុំរឿង ០០៤ ឯកសារ A122/6.1/3 *សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំឲ្យរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤។

[33]សំណុំរឿង ០០៣ ឯកសារ D117/1/1/2 *[កោសលុប] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៦។

01530399



ភាគីនោះ ត្រូវបានអះអាងជាថ្មីទៀតនៅក្នុងសាលដីកាមួយរបស់ អ.ប.ជ ទាក់ទងនឹងគោលការណ៍រក្សាការសម្ងាត់លើករណីខ្វែងយោបល់រវាង ស.ច.ស[34]។

២៦. ចៅក្រមជាតិ និងអន្តរជាតិនៃ អ.ប.ជ ខ្វែងយោបល់លើបញ្ហាចោទថាតើសហព្រះរាជអាជ្ញាម្នាក់ អាចបំពេញកិច្ចដោយឯកតោភាគីបានដែរឬអត់ប្រសិនបើមិនបានធ្វើកំណត់ហេតុករណីខ្វែងយោបល់។ ផ្ទុយពីចៅក្រមជាតិ[35] ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានពិចារណាថា ការធ្វើកំណត់ហេតុករណីខ្វែងយោបល់មិនមែនជាបុរេលក្ខខណ្ឌដើម្បីបំពេញកិច្ចដោយឯកតោភាគីទេ ប្រសិនបើសហព្រះរាជអាជ្ញាដែលជំទាស់ បានសម្រេចថាមិនប្តឹងទៅ អ.ជ.ប ទេនៅពេលដែលករណីខ្វែងយោបល់កើតឡើង[36]។

២៧. ការសន្និដ្ឋានដែលថា ការធ្វើកំណត់ហេតុករណីខ្វែងយោបល់ជាលក្ខខណ្ឌតម្រូវចាំបាច់ ប៉ុន្តែការប្តឹងទៅ អ.ប.ជ មិនមែនជាលក្ខខណ្ឌតម្រូវចាំបាច់ទេ គឺជាការសន្និដ្ឋានដែលតម្រូវឱ្យបកស្រាយផ្ទុយគ្នាលើពាក្យ "*អាច*"(ដោយមិនមានការបង្ហាញថា ហេតុអ្វីបានជាត្រូវមានការបកស្រាយខុសគ្នាបែបនេះទេ) ហើយក៏ជាការសន្និដ្ឋានដែលបញ្ជាក់ថា ដោយសារថា វិធានផ្ទៃក្នុង ៧១ មាននីតិវិធីបន្ថែមជាមុនអំពីការធ្វើកំណត់ហេតុករណីខ្វែងយោបល់នោះ ទើបវិធានផ្ទៃក្នុង ៧១ មានអានុភាពជាងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក ទោះបីជាថា តាមឋានៈនុក្រម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក គឺជាប្រភពច្បាប់ខ្ពស់ជាងវិធានផ្ទៃក្នុងក៏ដោយ។ ហេតុនេះ យើងយល់ឃើញថា ទោះបីជាថា ចៅក្រម អ.ប.ជ មានមតិយោបល់ខុសគ្នាដូចបានកត់សម្គាល់ខាងលើក៏ដោយ ក៏មានការបង្ហាញឱ្យឃើញច្បាស់ថា

---

[34]សំណុំរឿង ០០៤ ឯកសារ D208/1/1/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣* ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១០។ ក្នុងសាលដីកានេះ អ.ប.ជ បានបញ្ជាក់ថា ករណីខ្វែងយោបល់គ្នាមិនត្រូវដាក់ចូលក្នុងសំណុំរឿងទេ "*លើកលែងតែការខ្វែងយោបល់គ្នានោះត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយ...*"(គូសបញ្ជាក់បន្ថែម)។

[35]សំណុំរឿង ០០៣ ឯកសារ D20/4/4 *[កោសលុប] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ ព័ន្ធនឹងសំណុំរឿង ០០៣* ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ៧, ១១។

[36]សំណុំរឿង ០០៣ ឯកសារ D20/4/4 *[កោសលុប] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ ព័ន្ធនឹងសំណុំរឿង ០០៣* ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ មតិយោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៤។

តាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ការធ្វើកំណត់ហេតុករណីខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា គឺជាបញ្ហាឆន្ទានុសិទ្ធិ។ ហេតុនេះ យើងមិនយល់ឃើញថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុង នូវវិធានការដោះស្រាយជម្លោះទេ។ នៅក្នុងសំណុំរឿង ០០៤/១ ទាំង ស.ព.ជ ទាំង ស.ព.អ បានយោងលើករណីខ្វែងយោបល់នៅក្នុងដីកាសន្និដ្ឋានស្ថាពររៀងខ្លួន ប៉ុន្តែ ការធ្វើរបៀបនេះគឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា[37]។

២៨. ហេតុនេះ យើងបដិសេធចំពោះការអះអាងរបស់មេធាវីការពារក្តី[38] ដែលថា សហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវស្វែងរកមធ្យោបាយទាំងអស់ដែលអាចមាន យោងតាមវិធានផ្ទៃក្នុង ៧១។ យើងក៏មិនយល់ឃើញថា យោងតាមវិធានផ្ទៃក្នុង ៧១(៤)(ឃ) អោ អាន មានសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុអំពីករណីខ្វែងយោបល់របស់សហព្រះរាជអាជ្ញាដែរ[39]។ សិទ្ធិបែបនេះអាចមានតែ*ក្នុងករណីដែល* អ.ប.ជ បានទទួលពិនិត្យករណីខ្វែងយោបល់តែប៉ុណ្ណោះ ហើយក្នុងករណីណាក៏ដោយ ក៏ ជនត្រូវចោទ មិនមានសិទ្ធិដោយស្វ័យប្រវត្តិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុអំពីករណីខ្វែងយោបល់ទេ[40] ប្រសិនបើ

---

[37]សំណុំរឿង ០០៤/១ ឯកសារ D304/1 *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ២-១១។ សំណុំរឿង ០០៤/១ ឯកសារ D304/2 *ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុងប្រឆាំងនឹង អ៊ឹម ចែម* ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ កថាខណ្ឌ ១១។

[38]សំណើ កថាខណ្ឌ ៣១។

[39]ដូចជើងទំព័រខាងលើ កថាខណ្ឌ ៣១។

[40]វិធានផ្ទៃក្នុង ៧១(៤)(ឃ) តម្រូវថា ចំពោះការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ អ.ប.ជ ក្រឡាបញ្ជីរបស់ អ.ប.ជ ត្រូវបញ្ជូនសេចក្តីសម្រេចនេះទៅឱ្យប្រធានការិយាល័យរដ្ឋបាល ដែលត្រូវជូនដំណឹងដល់សហព្រះរាជអាជ្ញា។ នេះស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងវិធានផ្ទៃក្នុង ៧១(២) ដែលតម្រូវថា ព័ត៌មានទាក់ទងនឹងការខ្វែងយោបល់មិនត្រូវដាក់ចូលក្នុងសំណុំរឿង ទេ។ វិធានផ្ទៃក្នុង ៧១(៤)(ឃ) ត្រូវធៀបជាមួយនឹងវិធានផ្ទៃក្នុង ៧២(៤)(ង) ដែលអនុវត្តដូចគ្នាផងដែរមកលើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នារបស់ ស.ច.ស ក្រៅពីមានលក្ខខណ្ឌតម្រូវបន្ថែមមួយទៀតដែលតម្រូវថា ភាគីក៏ត្រូវទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់ អ.ជ.ប ផងដែរ ក្នុងករណីដែលសេចក្តីសម្រេចនោះពាក់ព័ន្ធនឹងការខ្វែងយោបល់របស់ ស.ច.ស លើដីកាសម្រេចណាដែលភាគីណាមួយមានសិទ្ធិប្តឹងឧទ្ធរណ៍។ អ.ប.ជ បានបញ្ជាក់ពីខ្លឹមសារនេះនៃវិធានផ្ទៃក្នុង ៧២(៤)(ង) (*សូមមើល* សំណុំរឿង ០០៤/២ ឯកសារ D208/1/1/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣* ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១០)។ ហេតុនេះ យើងយល់ឃើញថា វិធានផ្ទៃក្នុង ៧១(៤)(ឃ) នៅពេលដែលបកស្រាយតាមបរិបទនៃវិធានផ្ទៃក្នុង ៧១(២)

នៅក្នុងកាលៈទេសៈពិសេសនៃសំណុំរឿង កង្វះព័ត៌មានអំពីករណីខ្វែងយោបល់បានប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ[41]។

២៩. ចំពោះ"*ក្តីរំពឹងយ៉ាងសមហេតុផល*"របស់មេធាវីការពារក្តី ដែលថា ជម្លោះបែបនេះត្រូវដោះស្រាយដោយ អ.ប.ជ នោះ យើងមិនយល់ឃើញថា មានក្តីរំពឹងទុកបែបនេះទេ ដោយពិនិត្យឃើញថា ការប្តឹងទៅ អ.ប.ជ គឺស្ថិតនៅក្នុងឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញា ហើយពិតណាស់ ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជាចែងយ៉ាងច្បាស់ថាក្នុងករណីដែលមិនមានដំណោះស្រាយ សំណុំរឿងត្រូវបន្តនីតិវិធី[42]។

៣០. ចំពោះចំណុចពេលវេលាដំបូងបំផុតដែលករណីខ្វែងយោបល់គ្នាលើដីកាសន្និដ្ឋានស្ថាពរ អាចត្រូវធ្វើកំណត់ហេតុនោះ[43] ចំណុចនេះគឺជាបញ្ហាដែលសហព្រះរាជអាជ្ញាជាអ្នកសម្រេច ប៉ុន្តែយើងពិតជាយល់ឃើញថា ដែនពេលវេលាបែបនេះក្នុងករណីខ្វែងយោបល់គ្នា អាចកំណត់បានល្អប្រសើរ គឺនៅមុនពេលដែលភាគីណាមួយ សម្រេចគោលជំហររបស់ខ្លួនថាត្រូវពិចារណាប្រើប្រាស់យន្តការពាក់ព័ន្ធក្នុងការដោះស្រាយជម្លោះ។ ជាងនេះទៀត ការកំណត់ជាកលាក់ផ្សេងពីនេះ ប៉ះពាល់ដល់គោលបំណងនៃយន្តការដោះស្រាយជម្លោះ ដែលត្រូវដោះស្រាយជម្លោះ មិនមែនផ្អឹបទុកជម្លោះទេ។

៣១. ចំពោះសេចក្តីព្រួយបារម្ភរបស់មេធាវីការពាក្តីដែលថាអាចទទួលបានដីកាសន្និដ្ឋានស្ថាពរពីរនោះ យើងមិនយល់ឃើញថា ជាគោលការណ៍ មានផលប៉ះពាល់ណាមួយកើតឡើងទេ ដោយសារថា មេធាវីការពារក្តី នឹងត្រូវផ្តល់ជូននូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតប ដូចបានបញ្ជាក់នៅក្នុងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ[44]។

## ខ. ភាពស្របច្បាប់នៃការដាក់ដីកាសន្និដ្ឋានស្ថាពរច្រើន (សំណើទី ២)

---

និងវិធានផ្ទៃក្នុង ៧២(៤)(ង) គឺបង្ហាញយ៉ាងច្បាស់អំពីចេតនារក្សាការសម្ងាត់រវាងសហព្រះរាជអាជ្ញាចំពោះការពិចារណានានារបស់សហព្រះរាជអាជ្ញា។

[41] សំណុំរឿង ០០៤/២ ឯកសារ D208/1/1/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣* ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ១០។

[42] ច្បាប់ អ.វ.ត.ក មាត្រា ២០ ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(៤)។

[43] សំណើ កថាខណ្ឌ ៣២។

[44] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ១១។

៣២. យើងយល់ស្របតាមមេធាវីការពារក្តី ដែលថា ខ្លឹមសារមួយនៃវិធានផ្ទៃក្នុង ៦៦(៥) ចែងអំពីដីកាសន្និដ្ឋានស្ថាពរមួយ ប៉ុន្តែ ភាសានេះ មិន *តម្រូវឱ្យមាន* ដីកាសន្និដ្ឋានស្ថាពរមួយរួមគ្នាទេ ហើយក៏មិនបានដកចេញនូវការដាក់ដីកាសន្និដ្ឋានដាច់ដោយឡែកពីគ្នាដែរ ហើយប្រសិនបើដកចេញនូវការដាក់ដីកាសន្និដ្ឋានដាច់ដោយឡែកពីគ្នានោះវិញ ខ្លឹមសារនៃវិធានត្រូវបានបន្ថែមឧទាហរណ៍ ដោយគ្រាន់តែបន្ថែមពាក្យថា "*ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា*" ឬ "*ដីកាសន្និដ្ឋានស្ថាពរមួយរួមគ្នា*"។ សហព្រះរាជអាជ្ញា ត្រូវធ្វើការរួមគ្នាដើម្បីរៀបចំសេចក្តីសន្និដ្ឋានចោទប្រកាន់[45] ប៉ុន្តែ ការដែលសហព្រះរាជអាជ្ញា អាចខ្វែងយោបល់គ្នា ត្រូវបានទទួលស្គាល់នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលតម្រូវឱ្យសហព្រះរាជអាជ្ញា "*សហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់*"[46] ហើយពិតណាស់ មានបទប្បញ្ញត្តិអំពីយន្តការដោះស្រាយជម្លោះ ដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ចែងយ៉ាងច្បាស់ថាអាចមានករណីខ្វែងយោបល់គ្នា"*ថាតើ ត្រូវបន្តការចោទប្រកាន់ដែរឬអត់*"[47]។

៣៣. ការពិចារណាថែមទៀតគឺថា ដីកាសន្និដ្ឋានស្ថាពរ ត្រូវយកមកពិចារណាឱ្យបានត្រឹមត្រូវស្របតាមកាតព្វកិច្ចរបស់យើង ដែលត្រូវផ្តល់សំអាងហេតុនៅក្នុងដីកាដំណោះស្រាយរបស់យើង ប៉ុន្តែ យើងមិនជាប់កាតព្វកិច្ចត្រូវទទួលយកខ្លឹមសារនៃដីកាសន្និដ្ឋានស្ថាពរណាមួយ ឡើយ (ព្រមទាំងខ្លឹមសារនៃសារតបរបស់មេធាវីការពារក្តី ទៅនឹងដីកាសន្និដ្ឋានបែបនេះផងដែរ) ហើយ ដោយសារថា មេធាវីការពារក្តី នឹងត្រូវផ្តល់ជូននូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយតបនោះ[48] ទើបជាគោលការណ៍ មិនមានផលប៉ះពាល់ណាមួយកើតឡើងដោយសារតែដាក់ដីកាសន្និដ្ឋានស្ថាពរពីរផ្ទុយគ្នាទេ។

៣៤. ចំពោះការអះអាងដែលថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរគឺដណ្តើមយក "*អំណាចផ្តាច់មុខ*" របស់ អ.ប.ជ យ៉ាងស្រួល ដើម្បីដោះស្រាយជម្លោះ[49]ដូចបានបង្ហាញខាងលើនោះ យើងមិន

---

[45] សំណើ កថាខណ្ឌ ២៥។ ច្បាប់ អ.វ.ត.ក មាត្រា ១៦។

[46] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(៤) (គូសបញ្ជាក់បន្ថែម)។

[47] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(៤)។

[48] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ១១។

[49] សំណើ កថាខណ្ឌ ២៧។

យល់ឃើញថា ការប្ដឹងទៅ អ.ប.ជ គឺជាលក្ខខណ្ឌតម្រូវចាំបាច់ទេ ហេតុនេះ មិនមានអំណាចផ្ដាច់មុខដែលត្រូវដណ្ដើមទេ។

៣៥. យើងយល់ឃើញថាមិនមានសំអាងហេតុសមហេតុផលទេចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្ដី អំពីបញ្ហាចោទថាតើខ្លួននឹងត្រូវឆ្លើយតបទៅនឹងដីកាសន្និដ្ឋានណាមួយក្នុងចំណោមដីកាសន្និដ្ឋានស្ដាពរពីរនោះ[50]។ មេធាវីការពារក្ដី នឹងឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ដាពរណាមួយ ឬដីកាសន្និដ្ឋានស្ដាពរទាំងពីរ តាមអ្វីដែលខ្លួនគិតថាសមស្រប ហើយនឹងត្រូវផ្ដល់ជូននូវពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការឆ្លើយតបបែបនេះ។ ដោយសារថា ដីកាសន្និដ្ឋានរបស់ ស.ព.ជ គាំទ្រមេធាវីការពារក្ដី ដោយច្រានចោលយុត្តាធិការបុគ្គល ទើបអាចយល់ឃើញថាមិនមានទឡ្ហីករណ៍បន្ថែមទៀតដែលមេធាវីការពារក្ដីត្រូវជំទាស់ឡើយ ហេតុនេះ មិនមានផលប៉ះពាល់កើតឡើងទេ។ ចំពោះបញ្ហា *"ឥទ្ធភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"* ដែលបង្ហាញឱ្យឃើញថា ការដែលសហព្រះរាជអាជ្ញាមិនបានឯកភាពគ្នាលើអង្គសេចក្ដីនៃសំណុំរឿងណាមួយ មិនគួរបន្ដដំណើរការនីតិវិធីសំណុំរឿងនោះទេ ដូចបានបង្ហាញខាងលើនោះ ច្បាប់ អ.វ.ត.ក ចែងយ៉ាងច្បាស់ថា ក្នុងករណីដែលយន្ដការដោះស្រាយជម្លោះ "បរាជ័យ"នោះ សំណុំរឿងនឹងបន្តនីតិវិធីទៅមុខ ចំណែកឯ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ចែងយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាអាចមិនឯកភាពលើផ្នែកការងារដ៏សំខាន់បំផុតនៅក្នុងការិយាល័យរបស់ខ្លួន ហើយចែងថាក្នុងស្ថានភាពបែបនេះ សំណុំរឿងត្រូវបន្តនីតិវិធីទៅមុខ[51]។ ជាងនេះទៀត ក្រោយពីទទួលពិនិត្យការស៊ើបសួរ ស.ច.ស មានការទទួលខុសត្រូវជាអ្នកសម្រេចថាតើ ជនណាម្នាក់ត្រូវបញ្ជូនទៅជំនុំជម្រះ ឬអត់ មិនមែនសហព្រះរាជអាជ្ញាជាអ្នកសម្រេចទេ[52]។

៣៦. ចុងក្រោយបង្អស់ មេធាវីការពារក្ដី មិនមានសំអាងហេតុគាំទ្រថាតើសំណើទី ២ ថាមានប្រយោជន៍យ៉ាងណាដើម្បីការពារសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការស៊ើបសួរ និងការជំនុំជម្រះស្របតាមច្បាប់។ ដោយសារមិនមានទឡ្ហីករណ៍ជាក់លាក់ទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភលើសិទ្ធិនេះ ទើបយើងមិនយល់ឃើញថាចាំបាច់ត្រូវដោះស្រាយចំណុចនេះថែមទៀតទេ។

---

[50]សំណើ កថាខណ្ឌ ២៦។

[51]កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិជាមួយរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(៤)។

[52]វិធានផ្ទៃក្នុង ៦៧(១)។

៣៧. យើងយល់ឃើញថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរគឺអនុលោមតាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក។

គ. ការបង្ហាញថាមានដីកាសន្និដ្ឋានស្ថាពរច្រើន (សំណើទី ១)

៣៨. ឥឡូវនេះ សំណើទី ១ ត្រូវទុកជាមោឃៈ ដោយពិនិត្យឃើញថា សហព្រះរាជអាជ្ញាទាំងពីរបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនហើយ[53]។

ឃ. ផលប៉ះពាល់នៃការខ្វែងយោបល់គ្នាមកលើពេលវេលានៃការចេញដីកាសន្និដ្ឋានស្ថាពរមួយ (ឬច្រើន)(សំណើទី ៤)

៣៩. ឥឡូវនេះ សំណើទី ៤ ត្រូវទុកជាមោឃៈ ដោយពិនិត្យឃើញថាសហព្រះរាជអាជ្ញាទាំងពីរបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនហើយ[54]។

៤០. បញ្ហានានាដែលបានបង្ហាញនៅក្នុងដីកាសម្រេចនេះអាចមានប្រយោជន៍ដល់ភាគី ដែលស្ថិតក្នុងដំណាក់កាលស៊ើបសួរផងដែរ ហេតុនេះ ជាការល្អគួរឱ្យភាគីសំណុំរឿង ០០៤ ទទួលបានដីកាសម្រេចនេះដែរ។

៤១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងចេញសេចក្តីណែនាំដោយឡែក ទាក់ទងនឹងការដាក់អត្ថបទថតចម្លងនៃសេចក្តីសម្រេចនេះ ក្នុងសំណុំរឿង ០០៣។

**តាមសំអាងហេតុខាងលើ យើង**[55] ៖

៤២. **ជូនដំណឹង** មេធាវីការពារក្តី ថា៖

---

[53] សូមមើលខាងលើ កថាខណ្ឌ ៩-១០។

[54]សូមជើងទំព័រខាងលើ។

[55] ស.ច.ស ចេញសេចក្តីជូនដំណឹងនេះរួមគ្នា ប៉ុន្តែ ដើម្បីទុកជាកំណត់ហេតុ ស.ច.ស ជាតិ សូមកត់សម្គាល់ថា ឯកសារនានាដែលបានដាក់ចូលក្នុងសំណុំរឿង០០៤ ត្រូវដាក់លេខបន្តពីឯកសារចុងក្រោយ ដែលបានដាក់មុនពេលចៅក្រម Siegfried Blunk លាលែងតំណែង ដោយមិនរាប់បញ្ចូលដីកា និងដីកាសម្រេចនានាដែលចេញដោយ ស.ច.ស បម្រុង Laurent Kasper-Ansermet ឡើយ។

ក. ឥឡូវនេះ សំណើសុំការបញ្ជាក់បំភ្លឺថាតើ សហព្រះរាជអាជ្ញាមានបំណងដាក់ដីកាសន្និដ្ឋានស្ថាពរមួយ ឬ ពីរត្រូវទុកជាមោឃៈ។

ខ. យើងយល់ឃើញថា ការដាក់ដីកាសន្និដ្ឋានស្ថាពរពីរផ្ទុយគ្នា គឺស្របច្បាប់តាមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក។

គ. យើងមិនយល់ឃើញថា សហព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវប្រើប្រាស់ទាំងស្រុងនូវវិធានការដោះស្រាយជម្លោះ យោងតាមវិធានផ្ទៃក្នុង ៧១ ទេ។

ឃ. ឥឡូវនេះ សំណើសុំការបញ្ជាក់បំភ្លឺអំពីផលប៉ះពាល់នៃការខ្វែងយោបល់គ្នាមកលើពេលវេលានៃការចេញដីកាសន្និដ្ឋានស្ថាពរ ត្រូវទុកជាមោឃៈ។

៤៣. **បដិសេធ** ផ្នែកផ្សេងទៀតទាំងអស់នៃសំណើ។

៤៤. **បង្គាប់ឲ្យ** ក្រឡាបញ្ជី ដាក់ដីកាសម្រេចនេះចូលក្នុងសំណុំរឿង ០០៤។

ភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juge d'instruction

**ចៅក្រម យូ ប៊ុនឡេង** **ចៅក្រម** Michael BOHLANDER